សហគមន៍ខ្មែរកម្ពុជាក្រោម
KHMER KAMPUCHEA KROM COMMUNITY
LA COMMUNAUTÉ DU KHMER KAMPUCHEA KROM

លេខ.................... ស.ខ.ក.ក.

# បឋកថា

## ស្វាគមន៍ឯកឧត្ដម MARCO PANELLA សមាជិកសភាសហគមន៍អឺរ៉ុប ប្រធានTRANSNATIONAL RADICAL PARTY

សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ

សូមគោរពឯកឧត្ដម MARCO PANELLA សមាជិកសភាសហគមន៍អឺរ៉ុប និងជាប្រធាន TRANSNATIONAL RADICAL PARTY និងគណៈប្រតិភូ

សូមគោរពភ្ញៀវកិត្តិយស និងបងប្អូនរួមជាតិជាទីស្នេហា

តាងនាមប្រជារាស្ត្រខ្មែរកម្ពុជាក្រោម និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្ដៅបំផុតចំពោះឯកឧត្ដមMARCO PANELLA សមាជិកសភាសហគមន៍អឺរ៉ុប និងជាប្រធានTRANSNATIONAL RADICAL PARTY ព្រមទាំងសមាជិក សមាជិកានៃគណៈប្រតិភូទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកបំពេញទស្សនកិច្ចនៅអង្គការ-សមាគមខ្មែរកម្ពុជាក្រោមយើងខ្ញុំ។ នេះជាលើកទី៤ហើយ ដែលយើងខ្ញុំមានកិត្តិយសបានទទួលស្វាគមន៍ឯកឧត្ដមMARCO PANELLA និងគណៈប្រតិភូមកបំពេញទស្សនកិច្ចនៅសហគមន៍យើងខ្ញុំ។

នេះជាការបង្ហាញឲ្យឃើញយ៉ាងច្បាស់អំពីទឹកចិត្តស្រឡាញ់យុត្តិធម៌ធម៌ ការលើកស្ទួយសិទ្ធិមនុស្ស ការការពារអ្នកទន់ខ្សោយ ដែលត្រូវអ្នកមានអំណាចរំលោភលើសិទ្ធិសេរីយ៉ាងពិតប្រាកដ ហើយក៏ជាការលើកទឹកចិត្តដ៏សំខាន់បំផុតដល់យើងខ្ញុំ ដែលកំពុងប្រយុទ្ធតស៊ូដើម្បីសិទ្ធិសេរីភាព សិទ្ធិជំនឿសាសនា និងការពារនូវអត្តសញ្ញាណជនជាតិដើម នៅលើទឹកដីកម្ពុជាក្រោម បច្ចុប្បន្នសាធារណរដ្ឋសង្គមនិយមវៀតណាមប៉ែកខាងត្បូងផងដែរ។ យើងខ្ញុំ បានកត់សំគាល់ឃើញថា ក្នុងតួនាទីជាប្រធានTRANSNATIONAL RADICAL PARTY និងជាសមាជិកសភាសហគមន៍អឺរ៉ុប ឯកឧត្ដមបានពលីកម្មដ៏ធំធេងក្នុងការជួយដល់ប្រជារាស្ត្រនានានៅជុំវិញពិភពលោកក្នុងការទាមទារឯករាជ្យ ស្វ័យភាព និងសិទ្ធិជនជាតិដើមជាដើម។

កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៨ កន្លងទៅកន្លងទៅថ្មីៗនេះ សមាជិក សមាជិកា សភាសហគមន៍អឺរ៉ុបបានបោះឆ្នោតគាំទ្រលើសេចក្ដីសំរេចជាប្រវត្តិសាស្ត្រមួយក្នុងការជំរុញឲ្យរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម គោរពសិទ្ធិសេរីភាពប្រជាពលរដ្ឋរបស់ខ្លួនឲ្យបានពេញលេញ តាមបទដ្ឋានសិទ្ធិមនុស្សអ[illegible]ជាតិ ជាពិសេស ប្រជាពរដ្ឋខ្មែរកម្ពុជាក្រោម។

សេចក្ដីសំរេចរបស់សភាសហគមន៍អឺរ៉ុប បានផ្ដល់នូវសេចក្ដីសង្ឃឹមយ៉ាងកក់ក្ដៅដល់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន ព្រោះថា ចាប់តាំងពីទឹកដីកម្ពុជាក្រោមបានធ្លាក់ទៅក្រោមការ

ត្រួតត្រារបស់អាណានិគមវៀតណាមកន្លងមក ពុំដែលមានអង្គការអន្តរជាតិណាមួយចាប់អារម្មណ៍ដល់សេចក្តីទុក្ខវេទនារបស់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមឡើយ។

ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ យើងខ្ញុំក្នុងនាមតំណាងប្រជារាស្ត្រខ្មែរកម្ពុជាក្រោមទាំងអស់ សូមសម្តែងនូវការគោរពនិងដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះឯកឧត្តមប្រធាន អនុប្រធាន សមាជិក សមាជិកាសភាសហគមន៍អឺរ៉ុបទាំងមូល ដែលបានធ្វើសេចក្តីសំរេចប្រកបដោយគតិបណ្ឌិតយ៉ាងត្រឹមត្រូវក្នុងការជួយសង្គ្រោះដល់ប្រជារាស្ត្រទូទៅក្នុងប្រទេសវៀតណាមឲ្យទទួលបានសិទ្ធិសេរីភាព។ សេចក្តីសំរេចនេះក៏បានផ្តល់នូវសេចក្តីសង្ឃឹមយ៉ាងកក់ក្តៅដល់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមជាង១៣.០០០.០០០នាក់(ដប់បីលាន)ថា ថ្ងៃណាមួយ និងបានរស់នៅក្នុងភាពសុខសាន្តប្រកបដោយសិទ្ធិសេរីភាពពេញលេញនៅលើទឹកដីកំណើតរបស់ខ្លួន ជាក់ជាមិនខាន។ យើងខ្ញុំត្រៀមខ្លួនជានិច្ច ក្នុងកិច្ចសហការ ប្រសិនបើត្រូវការយើងខ្ញុំ ដើម្បីជំរុញសេចក្តីសំរេចនេះឲ្យមានប្រសិទ្ធភាព។

ឯកឧត្តមប្រធាន និងគណៈប្រតិភូជាទីគោរព !

កម្ពុជាក្រោមមានផ្ទៃដី៦៨.៩៦៥គីឡូម៉ែត្រក្រឡា មានប្រជារាស្ត្រខ្មែរជាង១៣លាននាក់រស់នៅទាំង២១ខេត្តក្រុងរបស់កម្ពុជាក្រោម មានវត្តព្រះពុទ្ធសាសនា៥៦៧វត្ត។ តំបន់ដែលប្រជារាស្ត្ររស់នៅច្រើនជាងគេគឺ ខេត្តព្រះត្រពាំង(ត្រា វិញ) ឃ្លាំង(សុក ត្រាំង) មាត់ ជ្រូក(ចូវ ដុក) ព្រែក ឫស្សី(កឹង ថើ) មេ ស(មី ថ) ពលលាវ(បាក់ លីវ) ទឹក ខ្មៅ(កា ម៉ៅ) លង់ ហោ(វិញ ឡុង) ពាម(ហា តៀង) ពាម បារាជ្ញ(រ៉ាច យ៉ា)រោងដំរី(តី នីញ)។ប្រជារាស្ត្រខ្មែរទាំងនោះរស់នៅយ៉ាងវេទនាជាទីបំផុត សិទ្ធិជាមូលដ្ឋានរបស់មនុស្សត្រូវបាត់បង់ស្ទើតែទាំងស្រុង។ ដើម្បីជួយស្រោចស្រង់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមឲ្យបានរួចផុតពីការបាត់បង់ពូជសាសន៍និងទទួលបានសិទ្ធិសេរីភាព យើងខ្ញុំ សូមស្នើឯកឧត្តមក៏ដូចសភាសហគមន៍អឺរ៉ុប មេត្តាជួយអន្តរាគមន៍នូវបញ្ហាចាំបាច់មួយចំនួនដែលកំពុងកើតមានចំពោះប្រជារាស្ត្រខ្មែរកម្ពុជាក្រោម ដល់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមដូចខាងក្រោមៈ

១- ដោះលែងព្រះសង្ឃ៥អង្គ ដែលកំពុងជាប់ពន្ធនាគារនៅខេត្តឃ្លាំង ដោយឥតលក្ខខណ្ឌគឺ: ១-ភិក្ខុ ដាញ់ ទោន ២-ភិក្ខុតឹម មឿន ៣-ភិក្ខុថាច់ ធឿង ៤-ភិក្ខុលី ហ្វាង ៥-ភិក្ខុលី សឿង ។

២- បញ្ជូនព្រះតេជគុណទឹម សាខន ត្រឡប់មកព្រះរាជាណាចក្រកម្ពុជា ដើម្បីជួបជុំគ្រួសារ ។

៣- សូមឲ្យស្ថាប័នព្រះពុទ្ធសាសនាខ្មែរនៅកម្ពុជាក្រោម ស្ថិតនៅឯករាជ្យ មិនស្ថិតនៅក្រោមការត្រួតត្រារបស់បក្សកុម្មុយនិស្តវៀតណាម និងស្ថាប័នព្រះពុទ្ធសាសនាវៀតណាម។

៤-បញ្ឈប់ ការផ្លាសប្តូរសញ្ជាតិខ្មែរទៅជាសញ្ជាតិវៀតណាម(គិញ)ដោយមិនបានសួរសាមីខ្លួនឬចាប់បង្ខំប្រជារាស្ត្រខ្មែរ ឲ្យប្តូរសញ្ជាតិកំណើតរបស់ខ្លួនជាដើម។

៥-បញ្ឈប់ ការហៅខ្មែរកម្ពុជាក្រោមជាផ្លូវការថា "ខ្មែរណាមបោ"។ សូមរក្សាទុកឈ្មោះដើមដដែលគឺ "ខ្មែរក្រោមឬខ្មែរកម្ពុជាក្រោម" ។

៦-បញ្ឈប់ ការហាមឃាត់ក្នុងការទទួលពត៌មាន និងផ្សព្វផ្សាយពត៌មាន មានការប្រើប្រាសអ៊ីនធើណែតស្តាប់វិទ្យុពីបរទេស និងការផ្សព្វផ្សាយពត៌មានជាអក្សរ និងភាសាខ្មែរជាដើម។

៧-បញ្ឈប់ ការហាមឃាត់ក្នុងការប្រជុំ សម្តែងមតិខាងនយោបាយ និងការធ្វើបាតុកម្មជាដើម។

៨-បញ្ឈប់ រាល់ការសម្លុត គំរាមកំហែងតាមគ្រប់រូបភាពមកលើប្រជារាស្ត្រខ្មែរកម្ពុជាក្រោម។

THE KHMER KAMPUCHEA KROM COMMUNITY

៩-បញ្ឈប់ រាល់ការរឹបអូសយកដីធ្លីពីប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម។

១០-អនុញ្ញាតឲ្យមានការសិក្សារៀនសូត្រអក្សរសាស្ត្រខ្មែរដោយសេរី ជៀសវាងការតាមដាននិងត្រួតពិនិត្យដោយអាជ្ញាធរវៀតណាម។

១១-អនុញ្ញាតឲ្យមានការបង្កើតអង្គការ សមាគមក្រៅរដ្ឋាភិបាលដោយសេរី ដើម្បីការពារផលប្រយោជន៍សហគមន៍ខ្មែរកម្ពុជាក្រោម។

១២-អនុញ្ញាតឲ្យអង្គការសហប្រជាជាតិ និងសហគមន៍អឺរ៉ុប បើកការិយាល័យទទួលបន្ទុកសិទ្ធិមនុស្សនៅសាធារណរដ្ឋសង្គមនិយមវៀតណាម ជាពិសេសតំបនប្រជារាស្ត្រខ្មែររស។

យើងខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា បន្ទាប់ពីសភាសហគមន៍អឺរ៉ុបបានបោះឆ្នោតគាំទ្រលើសេចក្តីសំរេចស្តីអំពីប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងកិច្ចព្រមព្រៀងថ្មី ស្តីអំពីសហប្រតិបត្តិការនិងភាពជាដៃគូរវាងសហគមន៍អឺរ៉ុប និងវៀតណាមកាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៨ និងបន្ទាប់ពីឯកឧត្តមនិងគណៈប្រតិភូ បញ្ចប់ដំណើរទស្សនកិច្ចនៅសាធារណរដ្ឋសង្គមនិយមវៀតណាម ស្ថានភាពសិទ្ធិមនុស្សនៅទីនោះ ប្រាកដជាបានប្រសើរឡើងជាក់ជាពុំខាន។

ជាថ្មីម្តងទៀត យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម និងគណៈប្រតិភូដែលបានផ្តល់កិត្តិយសដ៏ធំធេងដល់យើងខ្ញុំ ដែលជាការបង្ហាញអំពីទឹកចិត្តអាណិតអាសូរដល់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមយើងខ្ញុំយ៉ាងពិតប្រាកដ។ តាមរយៈឯកឧត្តមផងដែរ យើងខ្ញុំសូមថ្លែងនូវអំណរគុណជាអតិបរមាចំពោះឯកឧត្តម លោកជំទាវ សមាជិក សមាជិកាសភាសហគមន៍អឺរ៉ុបទាំងអស់ ដែលបានបោះឆ្នោតគាំទ្រលើសេចក្តីសំរេចដ៏មានសារៈសំខាន់ ក្នុងការការពារសិទ្ធិសេរីភាពសហគមន៍ខ្មែរកម្ពុជាក្រោមយើងខ្ញុំនៅសាធារណរដ្ឋសង្គមនិយមវៀតណាម។ គុណបំណាចដ៏ធំធេងនេះ យើងខ្ញុំចងចាំជានិច្ចមិនអាចបំភ្លេចបានឡើយ។

ក្នុងឱកាសបុណ្យគ្រីស្មាសនិងចូលឆ្នាំសកល២០០៩ខាងមុខនេះ យើងខ្ញុំសូមគោរពជូនពរឯកឧត្តមនិងគណៈប្រតិភូ បានប្រកបដោយសុភមង្គលដ៏ត្រចះត្រចង់ក្នុងគ្រួសារ និងបានសំរេចគ្រប់ភារកិច្ចក្នុងបេសកកម្មការពារយុត្តិធម៌ និងលើស្ទួយសិទ្ធិមនុស្សជូនមនុស្សជាតិនៅលើសកលលោក។

សូមឯកឧត្តមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ភ្នំពេញថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៨

តំណាងអង្គការ-សមាគមខ្មែរកម្ពុជាក្រោម

ថាច់ សេដ្ឋា

អតីតសមាជិកព្រឹទ្ធសភា

ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម